ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៨៩
ចុះថ្ងៃទី ៖៣១-ខែឧសភា- ២០១៦
សាលក្រមលេខ ៖ ៣៨ " ក.២ "
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៧
សំណុំរឿងជំនុំជម្រះលេខ:៣៣៤
ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅ សាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ ០២ ។
កាលបរិច្ឆេទបើកសវនាការ ៖ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ២: ៣០រសៀល ។
កាលបរិច្ឆេទប្រកាសសាលក្រម ៖ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៣ : ០០រសៀល ។

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សា ។
លោក [redacted] ឋានៈចៅក្រម ជាចៅក្រមក្រុមប្រឹក្សា ។
លោកស្រី [redacted] ឋានៈចៅក្រម ជាចៅក្រមក្រុមប្រឹក្សា ។

### តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារង ជាតំណាងអយ្យការ ។

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជី ជាក្រឡាបញ្ជីសវនាការ ។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៥៨៩ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ដែលមានពិរុទ្ធជន ៖

-ឈ្មោះ [redacted] **មន្នីថត** (Harmony Todd ) ភេទប្រុស អាយុ១៦ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ សិស្ស កើតនៅភូមិពោធិបុស្ស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប (នៅលីវ) ឪពុកឈ្មោះ Bruce Todd (រ) ម្តាយឈ្មោះ [redacted] **ស្រីនាង** (រ) ទោសពីមុនគ្មាន ។ (**គេចខ្លួន**)

ត្រូវជាប់ចោទពីបទ៖ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងបទ៖ **រួមភេទជាមួយអនីតិជនក្រោមអាយុ១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **មន្នីថត** (Harmony Todd )។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**

-ឈ្មោះ [redacted] **អាគីម** ភេទស្រី អាយុ៤០ ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អាគីម** និងជនរងគ្រោះ [redacted] **សូរីយ៉ាវ៉ាចប៊ឺហ្គ** ( [redacted] sireya vunberg ) ។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **អាគីម** និងជនរងគ្រោះ [redacted] **សូរីយ៉ាវ៉ាចប៊ឺហ្គ** [redacted] sireya vunberg ) ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អាគីម** និងជនរងគ្រោះឈ្មោះ [redacted] **សូរីយ៉ាវ៉ាចប៊ឺហ្គ** ( [redacted] sireya vunberg ) ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] **អាគីម** និងជនរងគ្រោះ [redacted] **សូរីយ៉ាវ៉ាចប៊ឺហ្គ** ( [redacted] sireya vunberg ) ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១២២ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ : ៤៣០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ។

## <u>អង្គហេតុកើតមានឡើងដូចតទៅ៖</u>

កាលពីខែកញ្ញា ឆ្នាំ២០១៥ ឈ្មោះ [redacted] **មន្នីថត** (Harmony Todd ) ភេទ ប្រុស អាយុ១៦ ឆ្នាំ ជាតិ ខ្មែរ បានមកលេងជាមួយឈ្មោះ [redacted] **សូរីយ៉ាវ៉ាចប៊ឺហ្គ** ( [redacted] sireya vunberg ) ភេទ ស្រី អាយុ ១៣ ឆ្នាំ នៅផ្ទះរបស់ជនរងគ្រោះ ។ ឆ្លៀតពេលដែលឪពុក ម្តាយជនរងគ្រោះមិននៅផ្ទះឈ្មោះ [redacted] **មន្នីថត** (Harmony Todd )បានធ្វើសកម្មភាពចូលទៅក្នុងបន្ទប់របស់ជនរងគ្រោះ ហើយធ្វើសកម្មភាពផ្តួលជនរងគ្រោះទៅលើគ្រែ រួចខ្ទប់មាត់ជនរងគ្រោះរំលោភរហូតបានសម្រេច ហើយថែមទាំងគំរាមជនរងគ្រោះមិនឱ្យនិយាយរឿងនេះប្រាប់គេ ។ ក្រោយមកទៀតនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ពួកគេទាំងពីរនាក់ បានធ្វើសកម្មភាពរួមភេទជាមួយគ្នានៅក្នុងបន្ទប់ទឹកស្រីរបស់សាលារៀនអ៊ីនធើណេតស៊ិនណលស្គូលលអហ្វ សៀមរាប មានទីតាំងស្ថិតនៅភូមិសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ បន្ទាប់ពីពួកគេបារួមភេទហើយ ពួកគេបានដើរចេញពីបន្ទប់ទឹកម្តងម្នាក់ នៅពេលនោះសន្តិសុខនិងអ្នកបោសសំអាតឃើញក៏បានរាយការណ៍ឱ្យអ្នកគ្រប់គ្រង សាលាហើយមន្ត្រីអប់រំសាលាបានហៅពួកគេទៅអប់រំតែម្តង ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **មន្នីថត** ( [redacted] Todd )នៅដំណាក់កាលអយ្យការ បានឆ្លើយថា៖ ខ្លួនកើតនៅសហរដ្ឋអាមេរិក ហើយបានមករស់នៅស្រុកខ្មែរតាំងពីឆ្នាំ ២០១១ រហូតដល់ អំឡុងខែវិច្ឆិកា ឆ្នាំ ២០១៤

ទើបខ្លួនស្គាល់ឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) អាយុ ១៤ឆ្នាំ នៅអាងទឹកសណ្ឋាគារ ក្នុងកម្មវិធីវិសមកាលរបស់សាលារៀន។ ក្រោយមកខ្លួន និង [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) ខ្លួនតែងតែដើរលេងជាក្រុមរបស់សាលា ដោយពុំបានដើរលេងជាមួយគ្នាតែពីរនាក់នោះទេ ។ បន្ទាប់ពីសម្រាកនៅរដូវក្តៅមកពួកខ្លួនកាន់តែស្និតស្នាលនិងគ្នា ហើយបានដើរលេងជាមួយគ្នាក្នុងអំឡុងខែកក្កដា និងសីហា ក្នុងលក្ខណៈជាក្រុមសិស្សសាលា រហូតដល់ខែកញ្ញាទើបចូលកងវិញ ។ នៅពេលស្គាល់គ្នាខ្លួន ទើបតែមានអាយុ ១៤ ឆ្នាំ ឯឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ [redacted] sireya Wunberg ) មានអាយុ ទើបតែ១២ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែព័តមាននៅក្នុង facebook របស់គាត់ដាក់ថាអាយុ ២១ ឆ្នាំ ។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ខ្លួនពុំបានធ្វើសកម្មភាពចាប់រំលោភឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) នោះទេ ពីព្រោះថាក្នុងអំឡុងពេលនោះខ្លួននៅផ្ទះជាមួយម្តាយ ហើយមិនដឹងថាឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) នៅទីណាដែរ ។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ក្នុងបន្ទប់ទឹកសាលារៀនអន្តរជាតិ រូបខ្លួនពុំបានធ្វើសកម្មភាពចាប់រំលោភទៅលើឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ [redacted] sireya Wunberg ) នោះទេ ព្រោះបន្ទប់ទឹកមានពីរជាប់គ្នា ហើយក្នុងបន្ទប់ទឹកមួយមានទំហំ ១ ម៉ែត្របួនជ្រុង និងនៅជិតផ្លូវដើរ។ នៅក្នុងបន្ទប់ទឹកសាលារៀនមានសិស្សប្រុសស្រីចេញចូលទាំងអស់ ពុំមានបែងចែកដាច់នោះទេ ។ បន្ទាប់ពីចេញពីបន្ទប់ទឹករួចខ្លួនបានចូលក្នុងថ្នាក់រៀន ហើយគ្រូរបានហៅខ្លួនទៅការិយាល័យ ប៉ុន្តែពុំបានប្រាប់ពីមូលហេតុអ្វីនោះទេ ។ នៅពេលទៅដល់ឃើញឈ្មោះ [redacted] ូរីយ៉ាវ៉ាចបឺហ្គ [redacted] sireya Wunberg ) នៅទីនោះដែរ ដោយពេលនោះគ្រូរវិន័យបាននិយាយ ខ្លាំងៗដាក់ខ្លួនថាគាត់ស្អុកស្អាញ និងឈឺក្បាលនិងពួកខ្លួន ។ ខ្លួនធ្លាប់ទៅលេងផ្ទះឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ [redacted] sireya Wunberg ) ជាញឹកញាប់ ពេលខ្លះទៅម្នាក់ឯង និងពេលខ្លះទៀតទៅជាមួយមិត្តភ័ក្រ ប៉ុន្តែនៅពេលដែលទៅនោះគឺតែងតែមានអ្នកនៅជាមួយដូចជាយាយចុងភៅ និងប្អូនរបស់ឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) ។ ខ្លួនមិនដឹងថាម្តាយរបស់ឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) ប្តឹងរូបខ្លួនដោយសាររឿងអ្វីនោះទេ ប៉ុន្តែប្រហែលជាគាត់មិនពេញចិត្តនិងខ្លួនមានទំនាក់នងជាមួយនិងកូនរបស់គាត់ ។

-ជនរងគ្រោះឈ្មោះ [redacted] ស្វូរីយ៉ាវ៉ាចបឺហ្គ ( [redacted] sireya Wunberg ) បានឆ្លើយថា៖ ខ្លួននៅតែរក្សាចម្លើយរបស់ខ្លួននៅដំណាក់កាលអយ្យការដដែល ។ រឿងដែលមានការរួមភេទជាបន្តបន្ទាប់មកជាមួយឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) ក្នុងរឿងនេះគឺកើតចេញពីការរំលោភមកលើខ្លួនជាលើកដំបូង ពោលគឺសកម្មភាពលើកដំបូងដែលឈ្មោះ [redacted] មន្ទីថត [redacted] Todd ) បានប្រព្រឹត្តមកលើខ្លួននោះគឺជាអំពើចាប់រំលោភបង្ខិតបង្ខំ កាលពីខ្លួនមានអាយុ ១២ ឆ្នាំ មិនដឹងអ្វីទាំងអស់ ។ កាលពីថ្ងៃកើតហេតុឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) បានគោះទ្វារបន្ទប់ខ្លួនជាច្រើនដង ខ្លួនក៏បើក ទ្វារស្រាប់តែឈ្មោះ [redacted] មន្ទីថត ( [redacted] Todd )បានរុញទ្វារចូលហើយទាញខ្លួនផ្តួលទៅលើគ្រែ រួចចាប់ខ្ទប់មាត់រំលោភតែម្តង ខ្លួនព្យាយាមស្រែកដែរប៉ុន្តែគេខ្ទប់មាត់ជាប់ ។ ពេលរំលោភរួចឈ្មោះ [redacted]



Scanned with CamScanner

មន្ទីថត ( [redacted] Todd ) បានចេញទៅ និងបានគម្រាមថា បើរឿងនេះលិចឮដល់អ្នកដទៃនិងមានបញ្ហាអាក្រក់កើតឡើង ។ ចំណែកខ្លួនបានទៅប្រាយាយរបស់ខ្លួន ដោយសារខ្លួនឈឺ និងមានឈាមប្រឡាក់ប្រដាប់ភេទ និងមានឈាមហូរចេញមកក្រៅតិចៗដែរ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អាគីម បានឆ្លើយថា៖ខ្លួននៅតែរក្សាចម្លើយរបស់ខ្លួននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ នៅដដែល ។ នៅពេលដែលខ្លួនត្រឡប់មកពីភ្នំពេញវិញ ម្ដាយរបស់ខ្លួនបានប្រាប់ថា ឈ្មោះ [redacted] មន្ទីថត ( [redacted] Todd )បានមកលេងផ្ទះ ហើយនៅពេលដែលគេចេញទៅបាត់ឃើញកូនរបស់ខ្លួនយំ និងមានចេញឈាមហូរតាមភ្លៅ ។ នៅលើកទី២ ឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) បានរួមភេទជាមួយកូនស្រីរបស់ខ្លួនតាមរុនគូទនៅផ្ទះរបស់ខ្លួន ហើយកូនរបស់ខ្លួនបានស្រែកឱ្យជួយដែរប៉ុន្តែគ្មានអ្នកជួយ ហើយពេលនោះឈ្មោះ [redacted] មន្ទីថត ( [redacted] Todd )បានវាយជញ្ជាំងគំរាមមិនឱ្យស្រែក ។ លើកទី៣ ឈ្មោះ [redacted] ថត ( [redacted] Todd )បានឱ្យឈ្មោះ [redacted] ប្វូរីយ៉ាវ៉ាចបឺហ្គ [redacted] sireya Wunberg ) បៀមលិង្គរបស់គេទៀតផង ។ រឿងទាំងអស់នេះនាងខ្ញុំដឹងតាមកូនរបស់ខ្លួនជាអ្នកប្រាប់ ។ ខ្លួនតែងតែយកកូនស្រីរបស់ខ្លួនទៅមន្ទីរពេទ្យដើម្បីពិនិត្យព្រោះកូនរបស់ខ្លួនមានអាការខ្សោយ ។ ក្នុងរឿងនេះខ្លួនមានសាក្សីឈ្មោះ [redacted] គង់ ជាអ្នកបានឃើញកូនរបស់ខ្លួនយំ និងមានឈាមហូរ និងឈ្មោះ [redacted] ស៊ីវុត្ថាវ៉េនប៊ឺត [redacted] winberg ) ជាប្អូនជនរងគ្រោះ និងជាអ្នកឃើញបងស្រីយំនៅពេលគ្គុំភ្លួយជាមួយឈ្មោះ [redacted] មន្ទីថត [redacted] Todd ) ។

-សាក្សីឈ្មោះ [redacted] ភាន់ បានឆ្លើយថា៖កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ខ្លួនបានទៅបោសសំអាតបន្ទប់ទឹករបស់បុរស រួចបានដើរទៅផ្ទះបាយ ឯសន្តិសុខបានសាច់មាន់ក៏យកទៅលៀងនៅផ្ទះបាយជាប់បន្ទប់ទឹក បានឃើញសិស្សស្រីម្នាក់ដើរចេញពីបន្ទប់ទឹកទៅថ្នាក់រៀនវិញ លុះប្រហែលជា ៥ នាទី ក្រោយមកទើបឃើញសិស្សប្រុសម្នាក់ចេញពីបន្ទប់ទឹកសិស្សស្រីនោះដែរទើបខ្លួនបានរាយការណ៍ឱ្យគ្រប់គ្រងសាលាតែម្ដង ចំណែកសិស្សប្រុស និង សិស្សស្រីនោះខ្ញុំមិនដឹងថាគេធ្វើអ្វីនោះទេ ។

-សាក្សីឈ្មោះ [redacted] ចំរើន បានឆ្លើយថា៖ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ខាងអូសហ្វីសបានឱ្យខ្លួនឱ្យយកសាច់មាន់នៅបន្ទប់ផ្ទះបាយបន្ទប់ទឹកជាន់កណ្ដាល ហើយបានឃើញឈ្មោះ [redacted] ស៊ីតា ឡើងមកបន្ទប់ទឹកស្របគ្នាជាមួយឈ្មោះ [redacted] មន្ទីថត ពេលនោះខ្លួនមានការសង្ស័យបានមកហៅអ្នកអនាម័យឱ្យទៅជួយពិនិត្យមើលបានគ្នាពីរនាក់ ពេលទៅដល់ឃើញបន្ទប់ទឹកបុរសបើកទ្វារធម្មតា ឯបន្ទប់ទឹកខាងស្រីឃើញបិតទ្វារ បានប្រាំនាទីក្រោយមកឃើញឈ្មោះ[redacted] ស៊ីតា ចេញពីបន្ទប់ទឹក ហើយទ្វារបន្ទប់ទឹកនោះបិតជិតទៅវិញ ប្រហែលជា ២ នាទីក្រោយមកទើបឈ្មោះ ហម មន្ទីថត ចេញមក ហើយខ្លួនបានរាយការណ៍ឱ្យគ្រប់គ្រងសាលាតែម្ដង ។

- សាក្សីឈ្មោះ [redacted] ស្រួច និងឈ្មោះ [redacted] គង់ បានឆ្លើយប្រហាក់ប្រហែលគ្នាថា: នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ ខ្លួននិងប្រពន្ធបានឃើញឈ្មោះ [redacted] មន្ទីថត (Harmony Todd ) នៅវេលាម៉ោងប្រហែលជា៦ ល្ងាច ខ្លួននិងប្រពន្ធព្រមទាំងប្អូនប្រុសរបស់ឈ្មោះ [redacted] ស៊ីតា កំពុងអង្គុយមើលទូរទស្សន៍ស្រាប់តែឃើញឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) មកលេងជាមួយចៅស្រីរបស់ខ្លួននៅបន្ទប់

ទទួលភ្ញៀវ ។ បានមួយសន្ទុះក្រោយមកពួកខ្លួនបានឮសំឡេងទះទ្វារបន្ទប់ ប៉ុន្តែពួកខ្លួនមិនបានចូលទៅមើលនោះទេ មួយសន្ទុះក្រោយមកពួកខ្លួនបានឃើញឈ្មោះ [redacted] មន្នីថត ( [redacted] Todd ) ត្រឡប់ទៅវិញ ហើយចៅស្រីរបស់ខ្លួនឈ្មោះ [redacted] ស៊ីតា បានយំប្រាប់ខ្លួន ហើយយកដៃអង្អែលក្បាលពោះ ដោយនិយាយភាសាបរទេសទើបខ្លួនស្តាប់មិនបានមិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ ។ ឈ្មោះ [redacted] មន្នីថត (Harmony Todd ) បានសរសេរជាភាសាបរទេសអំពីទង្វើដែលគេធ្វើមកលើឈ្មោះ [redacted] ស៊ីតា ជាច្រើនទៀត ប៉ុន្តែខ្លួនពុំបានដឹងថាសរសេរអ្វីខ្លះនោះទេ លុះព្រឹកឡើងខ្លួនបានឃើញចៅស្រីរបស់ខ្លួនមានសភាពស្លេកស្លាំង រហូតដល់បីថ្ងៃក្រោយទើបម្តាយរបស់ឈ្មោះ [redacted] ស៊ីតា មកពីភ្នំពេញវិញ មកដល់ពួកខ្លួនបានប្រាប់រឿងរ៉ាវទាំងអស់ទៅគេ ទើបគេទំនាក់ទំនងម្តាយរបស់ឈ្មោះ [redacted]ន្នីថត ( [redacted] Todd ) មកប្រាប់រឿងរ៉ាវដែលកើតឡើងចំពោះកូន និងឱ្យទូន្មានកូនមិនឱ្យប្រព្រឹត្តអំពើរបែបនេះទៀត ។

-សាក្សីឈ្មោះ [redacted] ស៊ីវុត្តាវីនប៊ើត ( [redacted] winberg ) បានឆ្លើយថា:កាលពីថ្ងៃមិនចាំ ឆ្នាំ២០១៥ ពេលល្ងាច ឈ្មោះ [redacted]ន្នីថត ( [redacted] Todd ) បាមកលេងផ្ទះរបស់ខ្លួន រួចបានដោះអាវខាងក្រៅរបស់គេចេញដោយបាននិយាយថា ក្តៅរួចចូលទៅក្នុងបន្ទប់បងស្រីរបស់ខ្លួនដោយមិនដឹងថាចូលទៅធ្វើអ្វីនោះទេ បន្ទាប់មកឃើញបងស្រីរបស់ខ្លួនយំហើយរត់ទៅរកយាយរបស់ខ្លួនប្រាប់ ប៉ុន្តែមិនដឹងថានិយាយអ្វីនោះទេ ។ ឈ្មោះ [redacted]ន្នីថត ( [redacted] Todd ) បានមកលេងផ្ទះរបស់ខ្លួនជាច្រើនដង ព្រោះគេស្គាល់ខ្លួនជិតស្និតដែរ ។ នៅថ្ងៃមួយឪពុកម្តាយរបស់ខ្លួនមិននៅផ្ទះ នៅតែរូបខ្លួន យាយ និងតា ព្រមទាំងឈ្មោះ [redacted] ធី និងបងស្រីរបស់ខ្លួន ពេលនោះខ្លួនបានឃើញបងស្រីរបស់ខ្លួនដេកឃ្លុំភួយជាមួយឈ្មោះ [redacted] មន្នីថត ( [redacted] Todd ) និងបានឮបងស្រីរបស់ខ្លួនយំទៀតផង ។ ឈ្មោះ [redacted] មន្នីថត [redacted] Todd ) បានគំរាមថាបើសិនរឿងដែរគេនៅក្នុងបន្ទប់ជាមួយបងស្រីរបស់ខ្លួនលឺដល់អ្នកដទៃរូបគេនិងជាប់គុក ។

- ចម្លើយរបស់សាក្សីឈ្មោះ [redacted] ភាន់ បានឆ្លើយថា៖កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ខ្លួនបានឃើញឈ្មោះ [redacted] មន្នីថត ( [redacted] Todd ) និងឈ្មោះ [redacted] ស៊ីតា ដើរចេញពីបន្ទប់ទឹកតែមួយប៉ុន្តែពុំដឹងថាពួកគេធ្វើអ្វីនោះទេ ។

## មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានការពារថា

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ សូមតុលាការជួយរកយុត្តិធម៌ឱ្យកូនក្តីរបស់ខ្ញុំដោយក្តីអនុគ្រោះ ។

## តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា

ដោយឆ្លងតាមសវនាការនិងសួរដេញដោលខាងលើមកឃើញថាឈ្មោះ [redacted] មន្នីថត( [redacted] Todd ) ពិតជាបាន ប្រព្រឹត្តបទល្មើស: **រំលោភសេពសន្ថវៈ រួមភេទជាមួយអានីតិជនក្រោមអាយុ១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា

២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤២ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស ។ ហេតុដូចនេះ តំណាងអយ្យការដំកល់ដីកាសន្និដ្ឋានស្ថាពរដដែល ។

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្នុងនាមខ្ញុំជាមេធាវីការពារឲ្យជនរងគ្រោះ ឆ្លងតាមការសន្និដ្ឋានមក ខ្ញុំសូមឲ្យតុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសូមឲ្យអាណាព្យាបាលជនជាប់ចោទសងសំណងមកជនរងគ្រោះចំនួន ៥០.០០០០ ដុល្លារអាមេរិក(ហាសិបម៉ឺនដុល្លារអាមេរិក)និងសុំឲ្យធ្វើការបណ្តេញជនជាប់ចោទចេញពីប្រទេសកម្ពុជា។

លោក [redacted] មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរ និងការអានចម្លើយនៅពេលសវនាការឃើញថា៖ ខ្ញុំសូមតុលាការធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំឲ្យសរសេរឈ្មោះជនជាប់ចោទជាអក្សរឡាតាំងផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារ និងកំណត់ហេតុផ្សេងៗ ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

១-កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ពិតជាមានអំពើ **រំលោភសេពសន្ថវៈ និងរួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំ** មួយកើតឡើងនៅភូមិសាលាកំរើក សង្កាត់សាលាកំរើកក្រុងសៀមរាប ខេត្តសៀមរាប ដែលបង្កដោយពិរុទ្ធជនឈ្មោះ [redacted] **មន្ទីថត** ( [redacted] Todd ) បានធ្វើសកម្មភាពរំលោភសេពសន្ថវៈ រួមភេទជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំ ពិតប្រាកដមែន ។

២-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សូរីយ៉ាវ៉ាំចប៊ឺហ្គ** [redacted] sireya Wunberg) បានឆ្លើយថា៖ រូបខ្លួនពិតជាត្រូវ ឈ្មោះ [redacted] **មន្ទីថត** ( [redacted] Todd ) រំលោភសេពសន្ថវៈ និងបង្ខំរួមភេទតាមរុន្ធគូទ និងបង្ខំឲ្យមើលរឿងអាសអាភាសជាច្រើនលើក ។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អាគីម** បានឆ្លើយថា: កូនរបស់ខ្លួនពិតជាត្រូវបានឈ្មោះ [redacted] **មន្ទីថត** ( [redacted] Todd ) បង្ខំរួមភេទ ជាច្រើនលើកប្រាកដមែន ។

៤-តាមចម្លើយរបស់សាក្សីឈ្មោះលួន ភាន់ និងឈ្មោះ [redacted]ចំរើន ថា៖ពួកខ្លួនបានឃើញជនរងគ្រោះ និងជនជាប់ចោទចេញពីបន្ទប់ទឹកតែមួយនៅក្នុងសាលារៀន ហើយថែមទាំងបានរាយការណ៍ឱ្យអ្នកគ្រប់គ្រងសាលាទៀតផង ។

៥-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]ស្រួច និងឈ្មោះ [redacted] គង់ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុពួកខ្លួនបានឮសំឡេងទះទ្វារបង្គួច និងឃើញឈ្មោះ [redacted]ន្ទីថត [redacted] Todd ) ចេញពីក្នុងបន្ទប់ចៅស្រីរបស់ខ្លួនឈ្មោះ [redacted] សូរីយ៉ាវ៉ាំចប៊ឺហ្គ [redacted] sireya Wunberg) ហើយពេលនោះចៅស្រីរបស់ខ្លួនបានយកដៃអង្អែលពោះ និងយំរៀបរាប់ប្រាប់ពួកខ្លួនទៀតផង ប៉ុន្តែពួកខ្លួនស្តាប់មិនបាន ។

៦-តាមការពិនិត្យរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនរងគ្រោះ ព្រមទាំងចម្លើយរបស់សាក្សី និងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ ដែលអាចបញ្ជាក់ថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៧-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted]មន្ទីថត ([redacted] Todd ) បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសង្គម និងរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរូបរាងកាយ សេចក្តីថ្លៃថ្នូររបស់បុគ្គល ដ៏ទៃដែលច្បាប់ការពារ ។

៨-អំពើប្រព្រឹត្តរបស់ជនជាប់ចោទពិតជាផ្ទុយ និងច្បាប់ហើយតម្រូវឱ្យផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៩-ជនជាប់ចោទជាអនីតិជន ការយល់ដឹងពីទង្វើរបស់ខ្លួននៅមានកម្រិត តុលាការផ្តល់ប្រយោជន៍ដល់ជនជាប់ចោទតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

១០-លោកស្រី [redacted]មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារថា: ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធឱ្យជនរងគ្រោះ ឆ្លងតាមការសួរដេញដោលនៅ ពេលសវនាការមកឃើញថា កូនក្តីរបស់ខ្ញុំទើបតែមានអាយុ ១២ ឆ្នាំ ហើយរូបគេបានទំនាក់ទំនងជាមួយនិងជនជាប់ចោទតាមរយៈហ្វេសប៊ុក និងតាមការរៀនសាលាជាមួយគ្នា ។ ក្រោយមកម្តាយរបស់ជនរងគ្រោះបានធ្វើការហាមឃាត់ឈ្មោះ [redacted] មន្ទីថត ([redacted] Todd ) មិនឱ្យមានទំនាក់ទំនងជាមួយនិងកូនរបស់គាត់ទៀត ប៉ុន្តែឈ្មោះ [redacted]មន្ទីថត [redacted] Todd ) នៅតែមានទំនាក់ទំនងជាមួយនិងកូនក្តីរបស់ខ្ញុំទៀតរហូតដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឈ្មោះ [redacted] មន្ទីថត [redacted] Todd ) បានចូលទៅក្នុងបន្ទប់កូនក្តីរបស់ខ្លួន និងបានចាប់រំលោភ កូនក្តីរបស់ខ្ញុំ ។ ដោយឈ្មោះ[redacted] សូរីយ៉ាវ៉ាំចប៊ឺហ្គ ([redacted] sireya Wunberg ) ជាកូនរបស់ខ្ញុំមិនអាចតតាំងបានទើបឈ្មោះ [redacted] មន្ទីថត ([redacted] Todd ) ធ្វើសកម្មភាពរំលោភរហូតបានសម្រេច ។ ក្រោយពេលរំលោភរួចឈ្មោះ[redacted] សូរីយ៉ាវ៉ាំចប៊ឺហ្គ (Rosita sireya Wunberg ) បានប្រាប់ទៅជីដូនរបស់ខ្លួនដែរ ប៉ុន្តែជីដូនរបស់ខ្លួនស្តាប់មិនយល់ ដោយមូលហេតុគេនិយាយជាភាសាអង់គ្លេស ។ កណោយពេលរំលោភរួចឈ្មោះ[redacted]មន្ទីថត ([redacted] Todd ) បានគម្រាមកូនក្តីរបស់ខ្ញុំទាំងផ្ទាល់មាត់ និងទាំងសរសេរសារជាអក្សរទៀតផង មិនតែប៉ុណ្ណោះគម្រាមទៅលើប្អូនរបស់



Scanned with CamScanner

ជនរងគ្រោះទៀតផង ។ ក្នុងរឿងនេះតាមចម្លើយរបស់ជនជាប់ចោទបានបដិសេធថា រូបគេពុំបានប្រព្រឹត្ត អំពើរួមភេទទៅលើជនរងគ្រោះនោះទេ ប៉ុន្តែតាមរយៈការសរសេរសារជាអក្សរគឺគេពិតជាបានសរសេរ ពិតប្រាកដមែន ហេតុនេះសូមតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំឱ្យធ្វើការ បណ្តេញជនជាប់ចោទចេញពីប្រទេសកម្ពុជា ។ តុលាការមិនលើកយកការស្នើរសុំមកពិចារណា ដោយ ជនជាប់ចោទរូបនេះមានសញ្ជាតិខ្មែរ មានសិទ្ធរស់នៅក្នុងទឹកដីខ្មែរ ។

១១-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន ការពារថា: ឆ្លងតាមការសួរដេញដោល និងការអានចម្លើយនៅពេលសវនាការ បញ្ជាក់ឱ្យឃើញថា នៅថ្ងៃកើត ហេតុយាយរបស់ជនរងគ្រោះបានឃើញឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) រត់ចេញពីបន្ទប់និង ក្រោយមកឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) បានគម្រាមឈ្មោះ [redacted] សូរីយ៉ាវ៉ាំចប៊ឺហ្គ ( [redacted] sireya Wunberg ) មិនឱ្យប្រាប់រឿងនេះទៅអ្នកដទៃទៀតផង ហេតុនេះជនជាប់ចោទពិតជាបានចាប់រំលោភ ទៅលើជនរងគ្រោះប្រាកដមែន រឿងមួយទៀតការធ្វើកោសលវិច័យ កូនក្តីរបស់ខ្លួនពិតជាត្រូវបានរហែកក្រដាស់ ព្រហ្មចារិយ៍ ប្រាកដមែន ។ ឈ្មោះ [redacted] មន្ទីថត ( [redacted] Todd ) បានបង្ខំឱ្យកូនក្តីរបស់ខ្លួនមើលរឿង សិច និងរួមភេទជាមួយកូនក្តីរបស់ខ្លួនតាមមាត់ និងតាមរុនគូទទៀតផង ដែលទង្វើនេះជាទង្វើរួមភេទ ជាមួយអានិតិជនក្រោមអាយុ១៥ ឆ្នាំ ។ ឆ្លងតាមការសួរដេញដោលនៅក្នុងពេលសវនាការ សូមតុលាការ ធ្វើការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ហើយសូមសរសេរឈ្មោះជនជាប់ចោតជាអក្សរឡាតាំងផង ។

១២-មានពិរុទ្ធភាពធ្ងន់ល្មមលើ ឈ្មោះ [redacted] មន្ទីថត( [redacted] Todd ) ពិតជាបានប្រព្រឹត្ត បទល្មើស: **រំលោភសេពសន្ថវ រួមភេទជាមួយអានីតិជនក្រោមអាយុ១៥ ឆ្នាំ** ប្រព្រឹត្តនៅចំណុចភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥និងថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៣៩** នៃក្រមព្រហ្មទណ្ឌ និង មាត្រា **៤២** នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស។ ហេតុដូចនេះតំណាងអយ្យការដំកល់ដីកាសន្និដ្ឋាន ស្ថាពរដដែល ។

១៣-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលពេលសវនាការ ឆ្លងតាមការអាន ចម្លើយរបស់ជនជាប់ចោទ តាមចម្លើយរបស់សាក្សី , ចម្លើយជនរងគ្រោះ និងតាមការពិនិត្យសុតាងរួចមក ក្នុងនាមខ្ញុំ ជាតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល សូមតុលាការសម្រេចតាមច្បាប់ ។

១៤-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា: ឆ្លងតាមការសួរដេញដោលកូនក្តីខ្ញុំបាទឈ្មោះ [redacted] ន្ទីថត ( [redacted] Todd ) មានអាយុទើបតែ ១៤ ឆ្នាំ ប៉ុណ្ណោះ មិនអាចសរសេរសារជាអក្សរដោយមានការរៀបរៀងបានត្រឹមត្រូវនោះទេ ហេតុនេះក្នុងនាមខ្លួន ជាមេធាវីការពារសិទ្ធិឱ្យកូនក្តីរបស់ខ្លួន សូមច្រានចោលភស្តុតាងជាសារសរសេរជាអក្សរ ហេតុនេះសូម តុលាការជួយរកយុត្តិធ៌មឱ្យកូនក្តីរបស់ខ្លួនដោយក្តីអនុគ្រោះ ។

ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អាគីម បានប្ដឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥០.០០០០ ដុល្លារ (ហាសិបម៉ឺនដុល្លារអាមេរិក) តុលាការសម្រេចតាមភាពជាក់ស្ដែង ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្ដី</u>**

១-ផ្ដន្ទាទោសជនជាប់ចោទ៖ឈ្មោះ [redacted] មន្នីថត [redacted] T0dd) ភេទប្រុស អាយុ១៦ ឆ្នាំ ជាតិ ខ្មែរ ( ដែលមានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ (បួនឆ្នាំ) ។

**ពីបទ: រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា២៣៨ នៃ ក្រមព្រហ្មទណ្ឌ និងបទ៖ **រួមភេទជាមួយអាទីតិជនក្រោមអាយុ ១៥ ឆ្នាំ** ប្រព្រឹត្តនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៥ និង ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] មន្នីថត ([redacted] Todd) ភេទប្រុស អាយុ១៦ ឆ្នាំ ជាតិ ខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] មន្នីថត ([redacted] Todd) ភេទប្រុស អាយុ១៦ ឆ្នាំ ជាតិ ខ្មែរ សងសំណងជម្ងឺចិត្តចំនួន១០០,០០០.០០០រៀល(មួយរយលានរៀល) ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **អាគីម** ការទាមទារលើសពីនេះបដិសេធចោល ។

៤-សាលក្រមនេះប្រកាសជាអសាធារណៈនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទ ។

ទុកសិទ្ធិឱ្យប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

សៀមរាប, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner